អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មានដោយអង្គភាពគាំពារជនរងគ្រោះ
# ការគាំទ្រយ៉ាងច្រើនចំពោះសំណងដល់ជនរងគ្រោះក្នុងរបបខ្មែរក្រហម

អង្គភាពគាំពារជនរងគ្រោះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានពិគ្រោះយោបល់ជាមួយ ដើមបណ្តឹងរដ្ឋប្បវេណី សមាគមជនរងគ្រោះ ដៃគូអនុវត្តគម្រោង ម្ចាស់ជំនួយ ស្ថាប័នរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធផ្សេងទៀត ដើម្បីកំណត់ និងបង្កើតគម្រោងផ្តល់សំណងដែលនឹងត្រូវដាក់ស្នើឡើងសម្រាប់សំណុំរឿង ០០២/០២។ ជាលទ្ធផល គម្រោងចំនួន ២៣ ត្រូវបានបង្កើតឡើង ក្នុងនោះ គម្រោងចំនួនប្រាំត្រូវបានដាក់ស្នើសុំការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា ចំណែកឯគម្រោងចំនួន ១៨ ផ្សេងទៀត បាននឹងកំពុងតែស្វះស្វែងរកការឧបត្ថម្ភថវិកាតាមរយៈប្រភពស្ថាប័នខាងក្រៅ។

ក្នុងករណីដែលជនជាប់ចោទត្រូវផ្តន្ទាទោស អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចឱ្យមានសំណងផ្លូវចិត្ត និងសមូហភាពដល់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រម ប្រសិនបើលក្ខខណ្ឌមួយចំនួនត្រូវបានបំពេញ។ ក្នុងចំណោមលក្ខខណ្ឌទាំងនោះ លក្ខខណ្ឌមួយគឺការផ្តល់ថវិកាគ្រប់គ្រាន់ពីប្រភពខាងក្រៅដល់គម្រោងសំណងនីមួយៗដែលបានស្នើសុំ។

មានគម្រោងសំណងចំនួន ១២ ក្នុងចំណោមគម្រោងទាំង ១៨ ដែលនឹងដាក់ស្នើសុំនៅក្នុងសំណុំរឿង ០០២/០២ បានទទួលការឧបត្ថម្ភថវិកាមួយផ្នែក ឬពេញលេញពីម្ចាស់ជំនួយមួយចំនួន រួមមាន សហភាពអឺរ៉ុប ក្រសួងសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់ Gesellschaft fuer Internationale Zusammenarbeit វិទ្យាស្ថានអាល្លឺម៉ង់សម្រាប់ទំនាក់ទំនងបរទេស ទីភ្នាក់ងារអភិវឌ្ឍន៍

និងសហប្រតិបត្តិការរបស់ប្រទេសស្វីស ស្ថានទូតប្រទេសស្វីសប្រចាំទីក្រុងបាងកក មូលនិធិ REI មូលនិធិ Heinrich Boll ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ និង International Coalitions of Site of Conscience។

ដើម្បីធានាថា ដើមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះក្នុងរបបខ្មែរក្រហមបានទទួលសំណងដ៏មានអត្ថន័យពាក់ព័ន្ធនឹងព្យសនកម្មដែលពួកគេបានទទួលរង ចាំបាច់ត្រូវមានជំនួយថវិកាបន្ថែមទៀត។ យើងសូមលើកទឹកដល់ចិត្តម្ចាស់ជំនួយទាំងអស់ ចូលរួមបំពេញការខ្វះខាតថវិកានេះ ដើម្បីផ្ដល់សំណងដល់ជនរងគ្រោះក្នុងរបបខ្មែរក្រហម។

អង្គភាពគាំពារជនរងគ្រោះគឺជាអង្គភាពផ្លូវការនៃ អ.វ.ត.ក. និងមានអាណត្តិការងារក្នុងការជួយគាំទ្រការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យប្ដឹងផ្សេងទៀតនៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការ។ អង្គភាពគាំពារជនរងគ្រោះ ដោយសហការជាមួយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ហើយក្នុងករណីចាំបាច់ ធ្វើការទំនាក់ទំនងជាមួយស្ថាប័នរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនានា ប្រឹងប្រែងកំណត់ រៀបចំ និងអនុវត្តគម្រោងសំណង។ លើសពីនេះទៀត អង្គភាពនេះក៏មានអាណត្តិការងារក្នុងការស្វែងរកជំនួយថវិកា និងការជួយជ្រោមជ្រែងពីស្ថាប័នខាងក្រៅដើម្បីអនុវត្តគម្រោងសំណងទាំងនេះ។

សូមពិនិត្យមើលតារាងភ្ជាប់មកជាមួយខាងក្រោមនេះសម្រាប់ព័ត៌មានអំពីសំណើគម្រោងសំណងដែលនឹងដាក់ស្នើឡើងក្នុងសំណុំរឿង ០០២/០២។

**ព័ត៌មានសម្រាប់ទំនាក់ទំនងអង្គភាពគាំពារជនរងគ្រោះ**

**លោក ហង្ស វណ្ណៈ**

ប្រធានអង្គភាពគាំពារជនរងគ្រោះ

អ៊ីម៉ែល៖ hang.vannak@eccc.gov.kh

**លោក ឌី ឈុនសុង**

ប្រធានកម្មវិធីសំណងនៃអង្គភាពគាំពារជនរងគ្រោះ

អ៊ីម៉ែល៖ dy.chhunsong@eccc.gov.kh

**លោក Thomas Truemper**

ទីប្រឹក្សាអង្គភាពគាំពារជនរងគ្រោះ

អ៊ីមែល៖ truemper.thomas@eccc.gov.kh

+++

## ព័ត៌មានសម្រាប់ទំនាក់ទំនងផ្នែកសារព័ត៌មាន

លោក នេត្រ ភក្ត្រា

អ្នកនាំពាក្យសាលាក្តីខ្មែរក្រហម

ទូរស័ព្ទដៃ៖ +៨៥៥ (0) ១២ ៤៨៨ ១៥៦

ទូរស័ព្ទលើតុ៖ +៨៥៥ (0) ២៣ ៨៦១ ៥៦៤

អ៊ីមែល៖ neth.pheaktra@eccc.gov.kh

លោកស្រី Hayat Abu-Saleh

មន្ត្រីព័ត៌មានសាធារណៈ

ទូរស័ព្ទដៃ៖ +៨៥៥ (0) ១២ ៤៨៨ ៩៣៦

ទូរស័ព្ទលើតុ៖ +៨៥៥ (0) ២៣ ៨៦០ ១៩១

អ៊ីមែល៖ abusaleh@un.org

## ឯកសារភ្ជាប់៖ និដ្ឋភាពរួមនៃគម្រោងផ្តល់សំណងដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងដាក់ស្នើឡើងក្នុងសំណុំរឿង ០០២/០២

### តារាងទី១៖ គម្រោងដែលស្វែងរកប្រភពថវិកាពីស្ថាប័នខាងក្រៅ

| ឈ្មោះគម្រោង | អ្នកអនុវត្តគម្រោង | សេចក្តីបរិយាយ | កំណត់សម្គាល់ |
|---|---|---|---|
| ១. ការលើកស្ទួយសុខភាព និង សុខុមាលភាពផ្លូវចិត្ត និងកាត់បន្ថយហានិភ័យនៃភាពក្រីក្រ និងការបដិសេធន៍ពីសង្គម ចំពោះដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន និងមនុស្សចាស់ទន់ខ្សោយផ្សេងទៀតនៅកម្ពុជា | អង្គការមនុស្សចាស់កម្ពុជា | គម្រោងលើកស្ទួយសុខភាព និងសុខុមាលភាពផ្លូវចិត្ត និងកាត់បន្ថយហានិភ័យនៃភាពក្រីក្រ និងការបដិសេធន៍ពីសង្គម ចំពោះមនុស្សចាស់ទន់ខ្សោយចំនួន ៣ ៦០០ នាក់ រួមទាំងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តបាត់ដំបង បន្ទាយមានជ័យ និងសៀមរាប។ គម្រោងនេះមានគោលបំណងជួយជ្រោមជ្រែង និងពង្រឹងបណ្តាញសមាគមមនុស្សចាស់ (OPA) លើកទឹកចិត្តប្រជាជននៅក្នុងសហគមន៍ជាគោលដៅក្នុងការស្វែងរកការព្យាបាលស្ថានភាពសុខភាពរូបរាងកាយ និងផ្លាស់ប្តូរឥរិយាបថ និងទម្លាប់មិនល្អ និងដោះស្រាយតម្រូវការចាំបាច់ផ្នែករូបរាងកាយ និងផ្លូវចិត្តឱ្យបានរួសរាន់ជាងមុន តាមរយៈការគ្រប់គ្រងមន្ទីរថែទាំសុខភាពបឋម និងការពិនិត្យសុខភាព និងតាមរយៈការផ្តល់ការអប់រំផ្នែកសុខភាពផ្លូវចិត្តជាមូលដ្ឋាន និងការធ្វើអន្តរាគមន៍នៅថ្នាក់សហគមន៍។ | ទទួលបានថវិកាមួយផ្នែកដោយ៖<br>• អង្គការមនុស្សចាស់កម្ពុជា |
| ២. ការលើកកម្ពស់ការព្យាបាល និងការផ្សះផ្សានៅកម្ពុជាតាមរយៈកិច្ចអន្តរាគមន៍ផ្នែកចិត្តសង្គម | អង្គការចិត្តសង្គមអន្តរវប្បធម៌ | គម្រោងលើកស្ទួយសុខុមាលភាពចិត្តសង្គមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២/០២ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) និងជំរុញដល់ការនិយាយការពិត និងការចងចាំនៅតាមសហគមន៍ជនបទនៅកម្ពុជា។ គម្រោងនេះមានគោលបំណងផ្តល់ការព្យាបាលផ្លូវចិត្តក្នុងអំឡុងពេលសក្ខីកម្ម ដល់ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២/០២ រៀបចំក្រុមជួយខ្លួនឯងនៅក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២/០២ និងភ្ជាប់ទំនាក់ទំនងជាមួយប្រជាជនដែល | ពុំទាន់មានការឧបត្ថម្ភថវិកា |

| | | | |
|---|---|---|---|
| | | រស់នៅជនបទ។ | |
| ៣. មជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍នៅភ្នំសំពៅ និង ការធ្វើទុក្ខបុកម្នេញខាងពុទ្ធសាសនិកជនក្នុងរបបខ្មែរក្រហម | អង្គភាពគាំពារជនរងគ្រោះ<br>អង្គការយុវសន្តិភាព<br>និងវិទ្យាស្ថានសន្តិភាពកម្ពុជា | គម្រោងបង្កើតបរិយាកាសសុវត្ថិភាពសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និង ប្រជាពលរដ្ឋក្នុងសហគមន៍ តាមរយៈការបង្កើតមជ្ឈមណ្ឌលសិក្សាសន្តិភាពនៅក្នុងសហគមន៍ភ្នំសំពៅ ការរៀបចំឯកសារនូវអ្វីដែលបានកើតឡើងទៅលើពុទ្ធសាសនិកជនក្នុងរបបខ្មែរក្រហម ការប្រមូល និងចងក្រងទស្សនាទាននៃការអភិវឌ្ឍន៍បុគ្គលជាវិជ្ជមាន និងភាពជាមេដឹកនាំដោយផ្អែកលើទស្សនៈពុទ្ធសាសនា និងការអភិវឌ្ឍន៍វិធីសាស្រ្តនានាដែលយកមកប្រើប្រាស់ ដើម្បីបញ្ចូលទស្សនាទាននានាដែលបានប្រមូល និងចងក្រងទៅក្នុងសង្គមកម្ពុជា និង សហគមន៍យុវជន។ | ពុំទាន់មានការឧបត្ថម្ភថវិកា |
| ៤. ផ្ទាំងគំនូរដើម្បីការចងចាំអំពីក្រាំងតាចាន់ | អង្គការយុវសន្តិភាព និង<br>វិទ្យាស្ថានសន្តិភាពកម្ពុជា | គម្រោងលើកកម្ពស់សង្គមកម្ពុជាប្រកបដោយសន្តិភាព និង មានស្ថិរភាព តាមរយៈការផ្តល់ការយល់ដឹងជាអចិន្រ្តៃយ៍ និងទទួលស្គាល់ផ្លូវការអំពីការឈឺចាប់ដែលបណ្តាលមកពីការជម្លៀសដោយបង្ខំក្នុងរបបខ្មែរក្រហម ការផ្តល់ទីកន្លែងដើម្បីភ្ជាប់ទៅរកអតីតកាលជាថ្មី កាន់ទុក្ខ និងចែករំលែកបទពិសោធន៍ និង ជម្រុញឱ្យមានការចូលរួមកាន់តែប្រសើរទៅក្នុងដំណើរការកាន់ទុក្ខ និងការចងចាំ។ | ផ្តល់ថវិកាទាំងមូលដោយ៖<br>• International Coalitions of Site of Conscience |
| ៥. រឿងរ៉ាវដែលមិនធ្លាប់បានគេដឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលចូលរួមក្នុងសំណុំរឿង ០០២/០២ នៅ អ.វ.ត.ក | អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា | គម្រោងរៀបរៀងសៀវភៅស្តីអំពីសាច់រឿងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់ឱ្យចូលរួមក្នុងសំណុំរឿង០០២នៅ អ.វ.ត.ក តែពុំមានឱកាសក្នុងការផ្តល់សក្ខីកម្មនៅចំពោះមុខសាលាក្តីឬចូលរួមនៅក្នុងគម្រោងសំណងណាផ្សេងទៀត។ គម្រោងនេះមានគោលបំណងបង្កើតរូបភាពកាន់តែពេញលេញនូវឧក្រិដ្ឋកម្មផ្សេងៗដែលខ្មែរក្រហមបានប្រព្រឹត្ត និងបទពិសោធន៍ផ្សេងៗរបស់អ្នករស់រានពីរបបខ្មែរក្រហម អនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីមានសំឡេងរបស់ខ្លួននៅក្នុងប្រវត្តិសាស្រ្តដែលប្រជាពលរដ្ឋទូទៅ និងជំនាន់ក្រោយបានដឹង និងទទួលស្គាល់ ជួយឱ្យមានការយកចិត្តទុកដាក់ ដល់ សំឡេងរបស់ពួកគេដែលជាធម្មតាត្រូវបានចាត់ទុកថាពុំមានអំណាច និងមិនសំខាន់ធ្វើឱ្យភាពយុត្តិធម៌ និងភាពធូរស្បើយកាន់តែមានអត្ថន័យ តាមរយៈការទទួលស្គាល់ និងបង្កើតឱកាសដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលពុំធ្លាប់មានឱកាសមក | ផ្តល់ថវិកាមួយផ្នែកដោយ៖<br>• មូលនិធិ Heinrich Boll |

| | | | |
|---|---|---|---|
| | | ផ្តល់សក្ខីកម្មនៅ អ.វ.ត.ក ឬ បានទទួលផលប្រយោជន៍ពីគម្រោងសំណងផ្សេងទៀត ដែលចូលរួមចំណែកដល់ដំណើរការរម្លឹកការចងចាំ យុត្តិធម៌ និងការផ្សះផ្សារ។ | |
| ៦. ការប្រកួតប្រជែងរបស់យុវជនក្នុងការតាក់តែងបទចម្រៀងស្តីពីការចងចាំនៅកម្ពុជា | អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន | គម្រោងតាក់តែងចម្រៀងស្តីពីការចងចាំក្នុងគោលបំណងបង្កើនការទទួលស្គាល់ដល់ការឈឺចាប់របស់អ្នករស់រានមានជីវិត និង ការបាត់បង់ក្នុងរបបខ្មែរក្រហម និង បង្កើនការប្តេជ្ញាចិត្តរបស់យុវជនឆ្ពោះទៅអនាគតពោរពេញដោយសន្តិភាព និង យុត្តិធម៌។ | ផ្តល់ថវិកាមួយផ្នែកដោយ៖<br>• ក្រសួងសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និង អភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់ តាមរយៈ Gesellschaft fuer Internationale Zusammenarbeit |
| ៧. ការអប់រំផ្នែកច្បាប់ និង សិទ្ធិពលរដ្ឋដល់ដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិភាគតិច | អង្គការការពារសិទ្ធិជនជាតិភាគតិច | គម្រោងផ្តល់កម្មវិធីអប់រំផ្នែកច្បាប់ និង សិទ្ធិពលរដ្ឋ ដើម្បីបង្កើនការយល់ដឹងអំពីភាពពាក់ព័ន្ធនៃការចុះឈ្មោះជាពលរដ្ឋ និង កសាងសមត្ថភាពក្នុងចំណោមសហគមន៍ ដើម្បីឲ្យមានការយល់ដឹងកាន់តែប្រសើរអំពីសិទ្ធិរបស់ពួកគេទៅតាមច្បាប់ជាតិ និង ប្រមូលផ្តុំដៃគូពាក់ព័ន្ធនៅកម្ពុជា ក្នុងការខិតខំប្រឹងប្រែងសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយស្ថិរភាព។ គម្រោងនេះមានគោលបំណងបង្កើតសម្ភារៈផ្សព្វផ្សាយសមរម្យ ស្តីពីការចុះឈ្មោះជាពលរដ្ឋសម្រាប់ក្រុមគោលដៅ និង រៀបចំការផ្សព្វផ្សាយ និងការលើកឡើងនូវចំណេះដឹងដល់ក្រុមគោលដៅ និង អាជ្ញាធរមូលដ្ឋាននៅក្នុងគម្រោងខ្ចីសហគមន៍ចំនួនបីដែលដើមបណ្តឹងរដ្ឋប្បវេណីរស់នៅ ស្ថិតនៅខេត្តកំពង់ឆ្នាំង ប្រទេសកម្ពុជា។ | ផ្តល់ថវិកាទាំងមូលដោយ៖<br>• ក្រសួងសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និង អភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់ តាមរយៈ Gesellschaft fuer Internationale Zusammenarbeit |
| ៨. ការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈការបណ្តុះបណ្តាល និង សិក្ខាសាលាសម្រាប់គ្រូបង្រៀន និងសាស្ត្រាចារ្យសាកលវិទ្យាល័យ | មជ្ឈមណ្ឌលឯកសារកម្ពុជា | គម្រោងបង្កើនឥទ្ធិពល ប្រសិទ្ធភាព និងស្ថិរភាពនៃការអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ គម្រោងនេះមានបំណងអភិវឌ្ឍការយល់ដឹងដល់គ្រូ និងសាស្ត្រាចារ្យពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងសមត្ថភាពរបស់ពួកគេអំពីវិធីសាស្ត្រនៃការអប់រំដែលផ្តោតលើសិស្ស-និស្សិត ប្រើប្រាស់សាច់រឿង និងបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នករស់រានមានជីវិត ដើម្បីផ្តល់នូវមធ្យោបាយសម្រាប់ការសន្ទនា និងការអប់រំស្តីពីរឿងរ៉ាវជីវិតរបស់បុគ្គលម្នាក់ៗក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ និងបង្កើនប្រសិទ្ធភាព និងស្ថិរភាពនៃកម្មវិធីអប់រំអំពីអំពើ | ផ្តល់ថវិកាមួយផ្នែកដោយ៖<br>• សហភាពអឺរ៉ុប តាមរយៈអង្គការ UNOPS |

| | | | |
|---|---|---|---|
| | | ប្រល័យពូជសាសន៍ តាមរយៈសិក្ខាសាលាអភិវឌ្ឍន៍វិជ្ជាជីវៈ និងការបោះពុម្ពផ្សាយ/ការចែកចាយសៀវភៅប្រវត្តិសាស្ត្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ | |
| ៩. កម្មវិធីសិក្សាអំពីរបបខ្មែរក្រហមតាមរយៈទូរស័ព្ទដៃ | មជ្ឈមណ្ឌលសោតទស្សន៍ បុប្ផាណា | គម្រោងបង្កើតកម្មវិធីតាមអ៊ិនធឺណេតសម្រាប់ឧបករណ៍អេឡិចត្រូនិកសម្រាប់ទូរស័ព្ទដៃ ដែលមានមូលដ្ឋានទិន្នន័យនៃប្រភពការសិក្សាសម្រាប់ចែករំលែកអំពី អ.វ.ត.ក និង សម័យកាលខ្មែរក្រហម។ គម្រោងនេះមានគោលបំណងធានាឱ្យមានការចូលប្រើប្រាស់ព័ត៌មានបានទូលំទូលាយ រក្សាការចងចាំជាប្រវត្តិសាស្ត្រ និងវប្បធម៌ គាំទ្រដល់ទំនាក់ទំនងស្អិតរមួតនៅក្នុងសង្គម លើកកម្ពស់ និងអប់រំអំពីសិទ្ធិមនុស្ស និងទទួលស្គាល់ភាពអយុត្តិធម៌។ | ផ្តល់ថវិកាទាំងស្រុងដោយ៖<br>• មូលនិធិ Rei<br>• សហភាពអឺរ៉ុប តាមរយៈអង្គការ UNOPS |
| ១០. ផ្កាស្លាក្រោមអង្គការ៖ អាពាហ៍ពិពាហ៍ដោយបង្ខំក្រោមរបបខ្មែរក្រហម | វិទ្យាស្ថានសិល្បៈខ្មែរ<br>មជ្ឈមណ្ឌលសោទស្សន៍ បុប្ផាណា<br>អង្គការក្តីករុណា<br>អង្គការចិត្តសង្គមអន្តរវប្បធម៌ | គម្រោងប្រែក្លាយការយល់ដឹងអំពីអំពើហិង្សាយេនឌ័រ និង សមភាពយេនឌ័រ តាមរយៈការរក្សាការចងចាំតាមបែបសិល្បៈអំពីបទពិសោធន៍ដែលបានចែករំលែក ការសន្ទនាអន្តរជំនាន់ ការរៀបចំឯកសារដែលមានការចូលរួម ការជួយជ្រោមជ្រែងដល់ការព្យាបាលផ្លូវចិត្ត និងការស្រាវជ្រាវពាក់ព័ន្ធនឹងអាពាហ៍ ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម។ | ផ្តល់ថវិកាមួយផ្នែកដោយ៖<br>• ក្រសួងសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និង អភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់ តាមរយៈអង្គការ Gesellschaft fuer Internationale Zusammenarbeit<br>• ទីភ្នាក់ងារអភិវឌ្ឍន៍ និងសហប្រតិបត្តិការរបស់ប្រទេសស្វីស<br>• វិទ្យាស្ថានអាល្លឺម៉ង់សម្រាប់ទំនាក់ទំនងបរទេស |
| ១១. វេទិកាអប់រំជាសាធារណៈ និងការតាំងពិពណ៌ជាអចិន្ត្រៃយ៍អំពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ | | គម្រោងលើកទឹកចិត្តឱ្យមានការពិភាក្សារវាងប្រជាពលរដ្ឋកម្ពុជានៅតាមភូមិ ដើម្បីស្វែងយល់ពីតួនាទីនៃការអប់រំអំពីអំពើប្រល័យពូជសាសន៍ចំពោះអនាគតនៅក្នុងសហគមន៍របស់ពួកគេ។ គម្រោងនេះមានគោលបំណងរៀបចំជាវេទិកាដើម្បីពិភាក្សាអំពីបទពិសោធន៍ក្នុងរបបខ្មែរក្រហមរបស់អ្នករស់រានមានជីវិត និង អំពីសារៈសំខាន់ | ពុំទាន់មានការឧបត្ថម្ភថវិកា |

| | | | |
|---|---|---|---|
| | មជ្ឈមណ្ឌលឯកសារកម្ពុជា | នៃការអប់រំអំពីអំពើប្រល័យពូជសាសន៍ លើកទឹកចិត្តឲ្យប្រជាពលរដ្ឋនៅតាមភូមិចូលរួមក្នុងការបង្រៀនអំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមដល់ក្មេងជំនាន់ក្រោយរបស់ពួកគេ ព្រមទាំងតាមដានដំណើរការបច្ចុប្បន្នភាពនៅ អ.វ.ត.ក និង ទាក់ទាញចំណាប់អារម្មណ៍ដល់សមាជិកសហគមន៍ដែលពុំបានអានសៀវភៅប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម ឬ យល់ដឹងអំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមតាមវិធីផ្សេងទៀត។ | |
| ១២. ការបោះពុម្ពផ្សាយ និង ការចែកចាយដល់ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២/០២ នូវសាលក្រមទាំងមូល និងសេចក្តីសង្ខេប | អង្គភាពគាំពារជនរងគ្រោះ | គម្រោងផ្តល់អត្ថបទទាំងមូលនៃសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ព្រមទាំងសំណៅសង្ខេបផ្លូវការនៃឯកសារនេះ។ គម្រោងនេះមានគោលបំណងធានាថា សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានព័ត៌មាន និងយល់ដឹងអំពីកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព បង្កើនភាពងាយស្រួលក្នុងការទទួលបានព័ត៌មានលម្អិតអំពីលទ្ធផលនៃរឿងក្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណី និង ជំរុញឲ្យមានការសន្ទនា និងការចូលរួមពីគ្រួសារ និងសហគមន៍ អំពីឧក្រិដ្ឋកម្មរបស់ពួកខ្មែរក្រហម និង ដំណើរការស្វែងរកយុត្តិធម៌។ | ពុំទាន់មានការឧបត្ថម្ភថវិកា |
| ១៣. គម្រោងអណ្តើកៈ គម្រោងអន្តរព័ត៌មានប្រកបដោយភាពច្នៃប្រឌិត ដើម្បីលើកកំពស់ការយល់ដឹងអំពីប្រវត្តិសាស្ត្រ និងភាពក្លាហានរបស់ជនស៊ីវិល (“អណ្តើកក្លាហាន”) | ផ្ទះមេត្តា | គម្រោងជំរុញឲ្យមានការផ្សះផ្សា និងការទប់ស្កាត់ជម្លោះនៅក្នុងសង្គមកម្ពុជា តាមរយៈការស្វែងរកការពិត និងបង្កើនការយល់ដឹងអំពីការរំលោភបំពានលើសិទ្ធិមនុស្សពីអតីតកាល និងនាពេលបច្ចុប្បន្ន ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងយុវជនជំនាន់ក្រោយ។ គម្រោងមានគោលបំណងរៀបចំការសម្តែង និងបញ្ចាំងភាពយន្តនៅតាមថ្នាក់រៀនអំពីអ្វីដែលបានកើតឡើងនៅអំឡុងរបបខ្មែរក្រហម និងផលប៉ះពាល់របស់វាទៅបច្ចុប្បន្ន ដើម្បីលើកទឹកចិត្ត សិស្សកម្ពុជាចាប់ផ្តើមការសន្ទនាជាមួយមនុស្សវ័យចំណាស់ អំពីអ្វីដែល បានកើតឡើងនៅក្នុងក្រោមរបបខ្មែរក្រហម | ផ្តល់ថវិកាទាំងស្រុងដោយៈ<br>• វិទ្យាស្ថានអាល្លឺម៉ង់សម្រាប់ទំនាក់ទំនងបរទេស<br>• សហភាពអឺរ៉ុប តាមរយៈអង្គការ UNOPS |
| ១៤. គម្រោងបណ្តាញព័ត៌មានសហគមន៍ៈ ប្រជាជនចាម និងខ្មែរក្រហម | ផ្ទះមេត្តា | គម្រោងស្វែងរកប្រវត្តិសាស្ត្រ និងបទពិសោធន៍ដែលមានលក្ខណៈពិសេស និងដែលមិនទាន់បានរាយការណ៍របស់ប្រជាជនចាមក្នុងរបបខ្មែរក្រហម ដែលបានប្រាប់តាមរយៈការឃើញផ្ទាល់ភ្នែក និងសាច់រឿងរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ | ផ្តល់ថវិកាទាំងស្រុងដោយៈ<br>• ស្ថានទូតប្រទេសស្វីសប្រចាំទីក្រុងបាងកក |

| | | | |
|---|---|---|---|
| | | | • មូលនិធិ Heinrich Boll |
| ១៥. គម្រោងបណ្ដាញព័ត៌មានសហគមន៍៖ ជនជាតិដើមភាគតិច និងខ្មែរក្រហម | ផ្ទះមេត្តា | គម្រោងនេះមានគោលបំណងជួយឲ្យផលិតករភាពយន្តក្មេងៗជាជនជាតិដើមភាគតិចក្នុងការផលិតខ្សែភាពយន្តឯកសារខ្លីៗអំពីការជួយជ្រោមជ្រែង/ការជ្រើសរើសក្រុមកុលសម្ព័ន្ធជនជាតិដើមភាគតិចដើម្បីចូលរួមក្នុងបដិវត្តន៍របស់ ប៉ុល ពត។ | ពុំទាន់មានការឧបត្ថម្ភថវិកា |
| ១៦. សំឡេងពីជនជាតិដើមភាគតិច៖ ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីការប្រព្រឹត្តមកលើជនជាតិដើមភាគតិចក្នុងអំឡុងរបបខ្មែរក្រហម | អង្គការក្ដីករុណា | គម្រោងបង្កើនការយល់ដឹងជាសាធារណៈអំពីបុព្វហេតុ និង ផលវិបាកនៃអំពើហិង្សាទៅលើជនជាតិភាគតិច និង ការរើសអើងចំពោះជនជាតិភាគតិចវៀតណាម និង ចាម ក្នុងរបបខ្មែរក្រហម និង ឥទ្ធិពលរបស់វាមកលើសង្គមបច្ចុប្បន្ន។ គម្រោងនេះមានគោលបំណងបង្កើតប្រវត្តិសាស្ត្រ និង រឿងរ៉ាវជីវិតរបស់ជនជាតិភាគតិច (ចាម និង វៀតណាម) លើកកម្ពស់ការពិភាក្សាអំពីអំពើហិង្សាទៅលើជនជាតិភាគតិច និងផ្ដល់វេទិកាដល់ដើមបណ្ដឹងរដ្ឋប្បវេណីជាជនជាតិចាម និង វៀតណាម រួមទាំងជនរងគ្រោះដោយសារអំពើហិង្សាទៅលើជនជាតិភាគតិច និង ការរើសអើងក្នុងរបបខ្មែរក្រហម ដើម្បីចែករំលែកសាច់រឿងរបស់ពួកគេ និង ដើម្បីទទួលបានការទទួលស្គាល់ជាសាធារណៈ។ | ផ្ដល់ថវិកាទាំងមូលដោយ៖<br>• ក្រសួងសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និង អភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់ តាមរយៈអង្គការ Gesellschaft fuer Internationale Zusammenarbeit<br>• ស្ថានទូតប្រទេសស្វីសប្រចាំទីក្រុងបាងកក |
| ១៧. គម្រោងចំណងអាពាហ៍ពិពាហ៍ | អង្គការយុវសន្តិភាព និងវិទ្យាស្ថានសភាកម្ពុជា | គម្រោងព្យាបាលផ្លូវចិត្ត និង ចងចាំដល់ជនរងគ្រោះដោយសារអាពាហ៍ ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម។ គម្រោងនេះមានគោលបំណងប្រើប្រាស់វិធី សាស្ត្រជាលក្ខណៈប្រពៃណីរបស់ខ្មែរដើម្បីព្យាបាលផ្លូវចិត្ត និង ចងចាំដល់ជនរងគ្រោះដោយសារអាពាហ៍ពិពាហ៍ដោយបង្ខំ តាមរយៈការសន្ទនាអន្តរជំនាន់ ការចងចាំឯកសារ និង កត់ត្រាការចងចាំ។ | ពុំទាន់មានការឧបត្ថម្ភថវិកា |
| ១៨. ការចូលមើល និងការផ្សព្វផ្សាយពីបណ្ណសារដ្ឋានច្បាប់ និងប្រវត្តិសាស្ត្រនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា | មជ្ឈមណ្ឌលឯកសារកម្ពុជា | គម្រោងមានគោលបំណងបង្កើតមជ្ឈមណ្ឌលធនធានអប់រំ ដែលមានបណ្ណសារដ្ឋានម្រាប់តម្កល់ឯកសារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រាប់ការប្រើប្រាស់ជាសាធារណៈនៅក្នុងខេត្តផ្សេងៗ ផ្សព្វផ្សាយបណ្ណាសារដ្ឋាននៅតាមសហគមន៍ដាច់ស្រយាលក្នុងប្រទេសកម្ពុជា បោះពុម្ពផ្សាយសៀវភៅការចងចាំ និងបង្កើតកម្មវិធីមែកធាងគ្រួសារក្នុងប្រព័ន្ធអ៊ីនធឺណែត។ | ផ្ដល់ថវិកាមួយផ្នែកដោយ៖<br>• ភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ |

**តារាងទី២៖ គម្រោងដែលស្វែងរកការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា**

| ឈ្មោះគម្រោង | ដៃគូអនុវត្តគម្រោង | កំណត់សម្គាល់ |
| --- | --- | --- |
| ១៩. សារមន្ទីរមជ្ឈមណ្ឌលសាធារណៈដើម្បីរម្លឹកការចងចាំ | រាជរដ្ឋាភិបាលកម្ពុជា | គម្រោងទាំងនេះទទួលបានគាំទ្រពីរដ្ឋាភិបាលកម្ពុជា។ ការិយាល័យរដ្ឋបាល និងអង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទទួលភារកិច្ចក្នុងការស្វែងរកការជួយជ្រោមជ្រែងផ្នែកថវិកា និងបច្ចេកទេសដើម្បីអនុវត្តគម្រោងទាំងនេះ។ |
| ២០. ពិធីបុណ្យជាសាធារណៈ | រាជរដ្ឋាភិបាលកម្ពុជា | |
| ២១. ការអភិរក្សទីតាំងឧក្រិដ្ឋកម្ម | រាជរដ្ឋាភិបាលកម្ពុជា | |
| ២២. ការដាក់ឈ្មោះដល់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលមានស្រាប់ | រាជរដ្ឋាភិបាលកម្ពុជា | |
| ២៣. មជ្ឈមណ្ឌលឯកសារច្បាប់ អ.វ.ត.ក | រាជរដ្ឋាភិបាលកម្ពុជា | សំណើគម្រោងនេះនឹងផ្ដល់ការប្រើប្រាស់ឯកសារតុលាការនៃតុលការខ្មែរក្រហម និងឯកសារដើមបណ្ដឹងរដ្ឋប្បវេណីនៅមជ្ឈមណ្ឌលឯកសារច្បាប់។ គម្រោងនេះបានទទួលការឧបត្ថម្ភថវិកា និងការជួយជ្រោមជ្រែងពីរដ្ឋាភិបាលជប៉ុន និងរដ្ឋាភិបាលកម្ពុជា។ បច្ចុប្បន្ន គម្រោងនេះដំណើរការក្រោមការគ្រប់គ្រងរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី។ |